# វិធីដាំខ្នុរ

## ១.ការជ្រើសរើសពូជ:

- គួរជ្រើសរើសពូជខ្នុរបំបៅពីព្រោះវាមានផ្លែសុទ្ធល្អនិងឆាប់បានផ្លែ។
- រើសយកពូជខ្នុរមានខ្លែបច្រើនសាច់ក្រាស់។

## ២.ការរៀបចំរណ្តៅ:

- ត្រូវជីករណ្តៅ៨តឹកបួនជ្រុង និង ជំរៅ៨តឹក




- រោយកំបោរសនិងថ្នាំកណ្តៀរ (FURADAN) ប្រមាណ២ស្លាបព្រាបាយក្នុងរណ្តៅ។
- ត្រូវដាក់ផេះឬអង្កាម, កំប្លោក, ចំបើងពុក, អាចម៍គោមាន់-ជ្រូកមួយស្រទាប់




កំរាស់១តឹករួចដាក់ដីពីលើ១តឹកធ្វើយ៉ាងនេះរហូតទាល់តែពេញកំពុងរណ្តៅ។

- ត្រូវទុករណ្តៅរៀបចំហើយក្នុងរយៈពេល២ ទៅ ៣ អាទិត្យ។
- ចំងាយពីរណ្តៅមួយទៅរណ្តៅមួយទៀត មាន ប្រវែង៨ម៉ែត្រ។

## ២.ការដាំ:

- កូនខ្នុរត្រូវរក្សាផ្សាំទុក១អាទិត្យមុនដាំ
- ផ្អាកស្រោចទឹកកូនខ្នុរ២ថ្ងៃមុនដាំ។
- មុនដាំត្រូវជញ្ជូនកូនដាក់ក្បែររណ្តៅ។
- ត្រូវបកថង់ចេញធ្វើយ៉ាងណាកុំអោយបែកដី
- ដាំកូនខ្នុរក្នុងរណ្តៅ រួចកប់ក្នុងដីដោយរក្សាថង់រុំបំបៅនៅលើដីប្រហែល១ថ្នប់ដៃ។
- លប់ដីដោយសង្កត់ថ្នមៗរួចយកមែកឈើដោតក្បែររណ្តៅចងទប់ជាមួយកូនខ្នុរ។




## ៣.ការថែទាំនិងដាក់ជី:

- កាត់ថង់រុំបំបៅចេញក្រោយដាំបាន១ខែ។
- ខែវស្សារត្រូវពូនគល់ការពារទឹកលិច។
- នៅដើមរដូវប្រាំងគួរដាក់ជីបំប៉នដោយប្រើជី១៥-១៥-១៥ (៣ខាំ)លាយជាមួយជីអាចម៍គោ, មាន់, ជ្រូក,(៣បង្គី) អង្កាម, ចំបើងរួចកាយកប់ក្នុងដីធ្វើជាកំពែង។
- ប្រសិនបើកូនខ្នុរមានសត្វល្អិតស៊ីត្រួយត្រូវ
- ប្រើថ្នាំសំលាប់សត្វល្អិតឬថ្នាំ S85 (កាបារីល)សំរាប់ជំនួយស្លឹកនិងដើមលូតលាស់ល្អ។



## ៤.ការស្រោចទឹក:

- កូនខ្នុរអាយុតិចជាង១ឆ្នាំត្រូវស្រោចទឹក២ដងក្នុង១អាទិត្យនៅរដូវប្រាំង។
- យើងត្រូវស្រោចទឹក១ដងក្នុង១អាទិត្យនៅពេលវាកំពុងផ្កាដើម្បីកាពោរជ្រុះក្តិប។